# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ   សាសនា   ព្រះមហាក្សត្រ

សង្គ្រោះ   បម្រើ   ការពារ

# លក្ខន្តិកៈ

## របស់

# គណបក្សសង្គ្រោះជាតិ

By-Laws

Cambodia National Rescue Party ( C.N.R.P. )

# បុព្វកថា

ដោយយល់ឃើញថា ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរបានឆ្លងកាត់នូវមហាសោកនាដកម្ម អំពើរំលោភសិទ្ធិមនុស្ស ការវិនាសអន្តរាយ ការឈ្លានពានពីបរទេស និងភាពក្រីក្រ រកបញ្ចប់មិនឃើញ ។

ដោយយល់ឃើញថា ប្រទេសកម្ពុជា បានឆ្លងកាត់នូវបទពិសោធន៍ជាមួយរបបដឹកនាំបែបកុម្មុយនីស្ត និងរបបផ្តាច់ការ ល្មមគ្រប់គ្រាន់ដល់ពេលវេលាកែប្រែការដឹកនាំប្រទេសតាមបែបប្រជាធិបតេយ្យ សេរីពិតប្រាកដហើយ ។

ដោយយល់ឃើញថា ដើម្បីឲ្យប្រទេសកម្ពុជាមានស្ថេរភាពនយោបាយ មានការរីកចម្រើនជឿនលឿន និងដើម្បីឲ្យប្រជាពលរដ្ឋមានជីវភាពធូរធារ សុខុដុមរមនា សម្បូរសប្បាយ លុះណាតែមានការគ្រប់គ្រង និងដឹកនាំប្រទេសតាមប្រព័ន្ធប្រជាធិបតេយ្យសេរី ដែលអំណាចពិតប្រាកដនៅក្នុងដៃប្រជាពលរដ្ឋ ដោយផ្តើមចេញពីការកសាងគណបក្សនយោបាយមួយដែលមានលក្ខណៈប្រជាធិបតេយ្យពិតប្រាកដ ដែលជាគណបក្សកើតចេញពីការប្រមូលផ្តុំអ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ ។

យើងខ្ញុំទាំងអស់គ្នាជាអតីតសមាជិក សមាជិកា គណបក្ស សម រង្ស៊ី គណបក្សសិទ្ធិមនុស្ស រួមនិងអ្នកប្រជាធិបតេយ្យផ្សេងទៀតបានរួមគ្នាបង្កើតគណបក្សនយោបាយមួយដែលមានឈ្មោះ និងមានគោលនយោបាយ ដូចតទៅ ៖

# ជំពូកទី ១

## ឈ្មោះ សញ្ញាសម្គាល់ និងទីស្នាក់ការ

**ប្រការ ១ ៖**

គណបក្សនយោបាយនេះ មានឈ្មោះថា " **គណបក្សសង្គ្រោះជាតិ** " ជាភាសាអង់គ្លេស " Cambodia National Rescue Party " សរសេរអក្សរកាត់ជាភាសាខ្មែរ " **គ.ស.ជ.** " និងជាភាសាអង់គ្លេស " C.N.R.P. " ។

**ប្រការ ២ ៖**

គណបក្សសង្គ្រោះជាតិ មានរូបសញ្ញា **ព្រះអាទិត្យរះ** បញ្ចេញកាំរស្មី២៤ជាសញ្ញាសម្គាល់ ។ អត្ថន័យនៃរូបសញ្ញានេះមានចែងនៅក្នុងឧបសម្ព័ន្ធទី១ ។

គណបក្សសង្គ្រោះជាតិ មានបាវចនា **សង្គ្រោះ បម្រើ ការពារ** ។

**ប្រការ ៣ ៖**

ទីស្នាក់ការកណ្តាលគណបក្សតាំងនៅផ្ទះលេខ៥៧៦ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ទីស្នាក់ការនេះអាចផ្លាស់ប្តូរទៅតាំងនៅទីកន្លែងផ្សេងទៀតបាន តាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

គណបក្សអាចបើកទីស្នាក់ការ ដែលជាសាខានៅរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងភូមិ ទូទាំងប្រទេស និងមានសាខានៅតាមប្រទេសនានាលើសកលលោក ។

**ប្រការ ៤ ៖**

គណបក្សសង្គ្រោះជាតិ កំណត់យកថ្ងៃបង្កើតគណបក្សជាផ្លូវការនៅ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ ជាថ្ងៃដែលថ្នាក់ដឹកនាំគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានសម្រេចបង្កើតគណបក្សសង្គ្រោះជាតិ ។

# ជំពូកទី ២

## ទស្សនវិស័យ គោលបំណង និងគោលនយោបាយ

**ប្រការ ៥ ៖**

គណបក្សសង្គ្រោះជាតិ ប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៦ ៖**

គណបក្សសង្គ្រោះជាតិ មានទស្សនវិស័យចង់ឃើញ " ប្រជាពលរដ្ឋខ្មែរ ធ្វើជាម្ចាស់ទឹកដីនៃមាតុភូមិកម្ពុជា និង ធ្វើជាម្ចាស់អំណាចពិតប្រាកដ " ។

**ប្រការ ៧ ៖**

គណបក្សសង្គ្រោះជាតិ មានគោលបំណងប្រមូលផ្តុំកម្លាំងប្រជាពលរដ្ឋខ្មែរ អ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យ ទាំងក្នុង ទាំងក្រៅប្រទេស រួមគ្នាដើម្បី ៖

១. ការពារឯករាជភាព អធិបតេយ្យ បូរណភាពទឹកដីខ្មែរ ដោយប្រឆាំងអំពើឈ្លានពានពីបរទេសតាមគ្រប់រូបភាព

២. លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ឲ្យមានភាពធូរធារ ថ្លៃថ្នូរ ដោយប្រឆាំងអំពើពុករលួយ និងអយុត្តិធម៌សង្គម

៣. កសាងសង្គមកម្ពុជា តាមគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស ដោយប្រឆាំងនឹងអំណាចផ្តាច់ការ ។

**ប្រការ ៨ ៖**

គណបក្សសង្គ្រោះជាតិមានគោលនយោបាយដូចតទៅ ៖

១. ប្រជាធិបតេយ្យ សេរី ពហុបក្ស

២. លើកស្ទួយការពារ គោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ

៣. នីតិរដ្ឋ

៤. អហិង្សា

៥. ខ្មែរតែមួយ ផ្សះផ្សាជាតិ មិនយកខ្មែរណាជាសត្រូវ មិនគុំកួនសងសឹកខ្មែរ

៦. សមធម៌ខាងនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច

៧. ទទួលខុសត្រូវក្នុងការដឹកនាំ

៨. សីលធម៌សង្គម

៩. សេដ្ឋកិច្ចទីផ្សារសេរី ដើម្បីសង្គម ។

# ជំពូកទី ៣

# សមាជិកភាព

**ប្រការ ៩ ៖**

គណបក្សសង្គ្រោះជាតិ គឺជាអង្គការនយោបាយប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរី និងបើកចំហយ៉ាងទូលំទូលាយទទួលយកប្រជាពលរដ្ឋខ្មែរពីគ្រប់មជ្ឈដ្ឋានដែលគាំទ្រគោលនយោបាយរបស់គណបក្សជាសមាជិករបស់ខ្លួន ។ ប្រជាពលរដ្ឋខ្មែរ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចសុំចូលជាសមាជិករបស់គណបក្សបាន ។ បែបបទនៃការសុំចូលជាសមាជិក មានចែងក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

**ប្រការ ១០ ៖**

សមាជិករបស់គណបក្ស មាន៤ប្រភេទ ៖

- សមាជិកស្ថាបនិក
- សមាជិកកិត្តិយស
- សមាជិកសកម្ម
- និងសមាជិកគាំទ្រ ។

**ប្រការ ១១ ៖**

សមាជិកស្ថាបនិក គឺជាអ្នកផ្តួចផ្តើមបង្កើតគណបក្ស រៀបចំលក្ខន្តិកៈគណបក្ស និងសមាជលើកដំបូងរបស់គណបក្ស ។

**ប្រការ ១២ ៖**

សមាជិកកិត្តិយស គឺជាវរជន ដែលមានឈ្មោះល្បីល្បាញនៅលើឆាកជាតិ និងអន្តរជាតិ ដែលបានជួយឧបត្ថម្ភគាំទ្រយ៉ាងខ្លាំង ទាំងស្មារតី ទាំងមធ្យោបាយដល់គណបក្ស ។

**ប្រការ ១៣ ៖**

សមាជិកសកម្ម គឺជាសមាជិកដែលធ្វើសកម្មភាពតំណាងគណបក្សនៅគ្រប់លំដាប់ថ្នាក់ ស្របតាមគោលនយោបាយរបស់គណបក្ស ។ សមាជិកសកម្ម មានកាតព្វកិច្ចបង់ភាគទាន ជូនគណបក្សតាមការសម្រេច របស់គណបក្ស ។

សមាជិកសកម្ម គឺជាអ្នកជ្រើសរើសប្រតិភូតំណាងគណបក្សគ្រប់លំដាប់ថ្នាក់ ។ សមាជិកសកម្មរបស់គណបក្ស ត្រូវមានប័ណ្ណសម្គាល់ខ្លួនរបស់គណបក្ស និងមានសេចក្តីសម្រេចតែងតាំងជាផ្លូវការ ។

**ប្រការ ១៤ ៖**

សមាជិកគាំទ្រ គឺជាអ្នកដែលគាំទ្រគោលនយោបាយរបស់គណបក្សតែមិនចេញមុខធ្វើជាតំណាងគណបក្ស ។

**ប្រការ ១៥ ៖**

សមាជិកទាំងអស់របស់គណបក្ស លើកលែងតែសមាជិកគាំទ្រ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានា ដែលមានចែងក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស ហើយត្រូវអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចនានារបស់ គណបក្ស ។

**ប្រការ ១៦ ៖**

សមាជិកគណបក្សអាចបាត់បង់សមាជិកភាពរបស់ខ្លួនដោយ ៖

- មរណភាព
- ការសុំលាលែងជាលាយលក្ខណ៍អក្សរ ដាក់ជូនប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ឬដាក់ជូនប្រធានគណបក្ស
- ការបញ្ចប់សមាជិកភាពពីគណបក្ស ។

**ប្រការ ១៧ ៖**

ការបញ្ចប់សមាជិកភាពពីគណបក្ស ចំពោះសមាជិករូបណាដែលមិនគោរពលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងគណបក្ស ឬសេចក្តីសម្រេចនានារបស់គណបក្ស ឬធ្វើសកម្មភាពផ្ទុយពីផលប្រយោជន៍គណបក្ស ត្រូវសម្រេចឡើងដោយ ៖

- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ហើយមានការបើកផ្លូវតវ៉ារយៈពេល៧ថ្ងៃ មកគណៈកម្មាធិការវិន័យរបស់គណបក្ស ចំពោះសមាជិកសកម្មថ្នាក់ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងភូមិ
- គណៈកម្មាធិការវិន័យគណបក្ស ហើយមានការបើកផ្លូវតវ៉ារយៈពេល៧ថ្ងៃ មកគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្ស ចំពោះថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ។

សមាជិករូបណាដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្ស ត្រូវបាត់បង់តួនាទីទាំងអស់នៅក្នុងរចនាសម្ព័ន្ធគណបក្សដោយស្វ័យប្រវត្តិ ។

នីតិវិធីនៃការបញ្ចប់សមាជិកភាពពីគណបក្សមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

# ជំពូកទី ៤
# សិទ្ធិ និងករណីយកិច្ចរបស់សមាជិក

**ប្រការ ១៨ ៖**

សមាជិកគណបក្ស មានសិទ្ធិស្មើគ្នាក្នុងការចូលរួមសកម្មភាពជាប្រយោជន៍ដល់គណបក្ស មានសិទ្ធិឈរឈ្មោះជាតំណាងគណបក្សគ្រប់លំដាប់ថ្នាក់ រួមទាំងសិទ្ធិផ្តល់យោបល់ក្នុងការដឹកនាំគណបក្ស ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ។

សមាជិកគណបក្ស ដែលមានប័ណ្ណគណបក្សសម្គាល់ខ្លួន ត្រូវគោរពប្រតិបត្តិឲ្យបានហ្មត់ចត់ នូវវិន័យ និងក្រមសីលធម៌ដូចខាងក្រោមនេះ ៖

- ពល់ក្បួនច្បាប់ និងពល់សេចក្តីសម្រេចនានារបស់គណបក្ស
- ទំនៀមទម្លាប់ ប្រពៃណីជាតិ និងជួយគ្នា ដើម្បីធ្វើឲ្យសមាជិកគណបក្ស កាន់តែមានលក្ខណសម្បត្តិល្អប្រសើរឡើង ក្នុងការបម្រើ ការពារ និងជួយសម្រាលទុក្ខវេទនា របស់ប្រជាពលរដ្ឋ
- ពប់អានគ្នា និងទទួលស្គាល់ភាពថ្លៃថ្នូររបស់សមាជិកគណបក្សទាំងអស់ដោយជៀសវាង គំនិតមើលងាយគ្នា មនោសញ្ចេតនា អាត្មានិយម ឬការប្រកាន់ឋានៈ តួនាទី ឬការមើលបំណាំគ្នា
- សេរីភាពខាងជំនឿរបស់សមាជិកទាំងអស់មិនប្រកាន់ជនជាតិ សាសនា ឬក្រុមបក្សពួកនៅក្នុងគណបក្ស
- សមភាពយេនឌ័រ ដោយជៀសវាងការប្រមាថ រើសអើង ឬប្រព្រឹត្តិអំពើហិង្សាលើស្ត្រី គ្រប់រូបភាព
- គោរពសិទ្ធិជនពិការ ដោយជៀសវាងការប្រមាថរើសអើងគ្រប់រូបភាព ។

# ជំពូកទី ៥
# រចនាសម្ព័ន្ធគណបក្ស

**ប្រការ ១៩ ៖**

គណបក្សសង្គ្រោះជាតិមានរចនាសម្ព័ន្ធ ដូចតទៅ ៖

១. សមាជ

២. ក្រុមប្រឹក្សាជាតិ

៣. គណៈកម្មាធិការនាយក

៤. គណៈកម្មាធិការវិន័យ

៥. គណៈកម្មាធិការប្រតិបត្តិ

៦. គណៈកម្មាធិការអេចិន្ត្រៃយ៍

៧. រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ។

## ផ្នែកទី ១

## សមាជគណបក្ស

**ប្រការ ២០ ៖**

សមាជគណបក្ស គឺជាស្ថាប័នកំពូលរបស់គណបក្ស ។ សមាជចូលរួមដោយប្រតិភូតំណាងសមាជិកគណបក្ស ។

សមាជមានតួនាទី និងភារកិច្ច ដូចតទៅ ៖

- កំណត់ទិសដៅ និងគោលនយោបាយរបស់គណបក្ស ហើយអនុម័តសេចក្តីសម្រេចសំខាន់ៗដែលគណៈកម្មាធិការនាយកបានដាក់ជូន
- អនុម័តលក្ខន្តិកៈគណបក្ស
- ជ្រើសតាំងប្រធានគណបក្ស
- ផ្តល់សេចក្តីទុកចិត្តដល់សមាសភាពក្រុមប្រឹក្សាជាតិ
- ផ្តល់សេចក្តីទុកចិត្តដល់សមាសភាពគណៈកម្មាធិការនាយក ។

សេចក្តីសម្រេចរបស់សមាជ ត្រូវអនុម័តដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) លើកលែងតែការអនុម័តលើលក្ខន្តិកៈគណបក្ស ដែលត្រូវអនុម័តដោយសម្លេងភាគច្រើន (២/៣) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច ។

ការរៀបចំ ការប្រព្រឹត្តិទៅរបស់សមាជគណបក្ស សិទ្ធិ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងប្រធានគណបក្ស និងការផ្តល់សេចក្តីទុកចិត្ត ដល់សមាសភាពក្រុមប្រឹក្សាជាតិ និងសមាសភាពគណៈកម្មាធិការនាយក មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

**ប្រការ ២១ ៖**

សមាជ មានពីរប្រភេទ គឺ សមាជសាមញ្ញ និងសមាជវិសាមញ្ញ ។

១. សមាជសាមញ្ញ នឹងប្រារព្ធឡើងជាទៀងទាត់ រៀងរាល់៥ឆ្នាំម្តង ។ កាលបរិច្ឆេទ និងទីកន្លែង នៃសមាជនេះ នឹងកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

២. សមាជវិសាមញ្ញ នឹងប្រារព្ធឡើងអាស្រ័យទៅតាមការសម្រេចរបស់ប្រធានគណបក្ស ដោយមានការគាំទ្រដោយសម្លេងភាគច្រើន (២/៣) នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងមូល ឬតាមសំណើ ២/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូលដោយមានការគាំទ្រពីប្រធានគណៈកម្មាធិការនាយក ។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានភារកិច្ចកោះប្រជុំ និងរៀបចំសមាជសាមញ្ញ និងវិសាមញ្ញ ហើយសមាជទាំងពីរប្រភេទនេះ ត្រូវតែប្រារព្ធឡើងក្រោមអធិបតីភាពរបស់ប្រធានគណបក្ស ។

**ប្រការ ២២ ៖**

ការអញ្ជើញសមាជិកគណបក្សមកចូលរួមសមាជ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃជាមុន ចំពោះសមាជសាមញ្ញ និង៧ថ្ងៃជាមុនចំពោះសមាជវិសាមញ្ញ ដោយមានបញ្ជាក់នូវរបៀបវារៈរបស់សមាជ ។

សមាជិកគណបក្ស ដែលមានលក្ខណៈជាតំណាង ហើយត្រូវអញ្ជើញមកចូលរួមសមាជ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាជាតិ

**ប្រការ ២៣ ៖**

ក្រុមប្រឹក្សាជាតិ ជាស្ថាប័នជាន់ខ្ពស់របស់គណបក្ស ដែលជួបប្រជុំ២ឆ្នាំម្តង ហៅថាសន្និបាតក្រុមប្រឹក្សាជាតិ ។ ក្រុមប្រឹក្សាជាតិ ជាប្រតិភូតំណាងឲ្យសមាជិកគណបក្សពីមូលដ្ឋាន និងមជ្ឈដ្ឋាននានា ដើម្បីចូលរួមសមាជគណបក្ស ។

ក្រុមប្រឹក្សាជាតិ មានសមាសភាព ៖

- គណៈកម្មាធិការអចិន្ត្រៃយ៍
- គណៈកម្មាធិការនាយក
- គណៈកម្មាធិការវិន័យ

- គណៈកម្មាធិការប្រតិបត្តិ
- ក្រុមការងាររាជធានី-ខេត្ត
- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត (ប្រធាន អនុប្រធាន លេខាធិការ និងហេរញ្ញិក)
- ប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ
- ប្រធាន និងអនុប្រធានចលនាមហាជនថ្នាក់ជាតិ
- ប្រធានចលនាមហាជនរាជធានី-ខេត្ត
- តំណាងគណបក្សមកពីមជ្ឈដ្ឋាននានា និងមកពីក្រៅប្រទេស ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

សមាសភាពក្រុមប្រឹក្សាជាតិនេះ ត្រូវបានផ្តល់សេចក្តីទុកចិត្តដោយសមាជគណបក្ស ។

**ប្រការ ២៤ ៖**

សន្និបាតក្រុមប្រឹក្សាជាតិ នឹងប្រារព្ធឡើងជាទៀងទាត់រាល់២ឆ្នាំម្តង ។ ទីកន្លែង កាលបរិច្ឆេទ និងរបៀបវារៈនៃសន្និបាតនេះ នឹងកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវប្រារព្ធឡើងក្រោមអធិបតីភាពរបស់ប្រធានគណបក្ស ឬអនុប្រធានគណបក្សតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្ស ។

សន្និបាតក្រុមប្រឹក្សាជាតិ ៖

- ធ្វើការពិភាក្សា អនុម័ត ឬផ្តល់សេចក្តីទុកចិត្តសេចក្តីសម្រេចនានារបស់គណបក្ស ដែលដាក់ជូនដោយគណៈកម្មាធិការនាយក ចន្លោះសមាជ
- អនុម័តគោលនយោបាយសំខាន់ៗរបស់គណបក្ស ។

សន្និបាតក្រុមប្រឹក្សាជាតិអាចប្រព្រឹត្តទៅបាន ចាំបាច់ត្រូវមានកូរ៉ុមភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកក្រុមប្រឹក្សាជាតិទាំងមូល ។ សេចក្តីសម្រេចរបស់សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវអនុម័តដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមាន ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់សន្និបាតក្រុមប្រឹក្សាជាតិ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

# ផ្នែកទី ៣
# គណៈកម្មាធិការនាយក

**ប្រការ ២៥ ៖**

គណៈកម្មាធិការនាយក គឺជាស្ថាប័ននីតិប្បញ្ញត្តិរបស់គណបក្ស ។ គណៈកម្មាធិការនាយកអនុវត្តទិសដៅ និងគោលនយោបាយរបស់គណបក្ស ដែលកំណត់ដោយសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ ។

គណៈកម្មាធិការនាយក មានសមាជិកយ៉ាងតិច៦៩រូប ដែលផ្ដល់សេចក្ដីទុកចិត្ត ដោយសមាជគណបក្ស សម្រាប់អាណត្តិ ៥ឆ្នាំ ។ បេក្ខជនគណៈកម្មាធិការនាយកត្រូវបានជ្រើសរើស ៖

- ពីតំណាងគណបក្សរាជធានី-ខេត្ត ដែលជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាជាតិតំណាងរាជធានី-ខេត្ត និងប្រធានគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ក្នុងរាជធានី-ខេត្តសាមី ។ ចំនួនបេក្ខជនគណៈកម្មាធិការនាយកតំណាងគណបក្សរាជធានី-ខេត្តនីមួយៗ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈតំណាងរាស្ត្រក្នុងរាជធានី-ខេត្តសាមី បូកមួយ ចែកនឹងពីរ ។
- ដោយគណៈកម្មាធិការនាយកតាមសំណើរបស់ប្រធានគណបក្ស ។ ចំនួនបេក្ខជនគណៈកម្មាធិការនាយកដែលជ្រើសរើសនេះមិនត្រូវលើសចំនួន ១/៣ នៃសមាជិកគណៈកម្មាធិការនាយកមកពីតំណាងគណបក្សរាជធានី-ខេត្ត ហើយត្រូវផ្ដល់អាទិភាពដល់យុវជន និងស្ត្រី ។

នីតិវិធីនៃការជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការនាយក មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

**ប្រការ ២៦ ៖**

គណៈកម្មាធិការនាយក បង្កើតគណៈកម្មាធិការវិន័យគណបក្សដូចមានចែងក្នុងផ្នែកទី៤ នៃលក្ខន្តិកៈនេះ ។

គណៈកម្មាធិការនាយក ជ្រើសតាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

គណៈកម្មាធិការនាយក ផ្ដល់សេចក្ដីទុកចិត្តដល់ប្រធាន និងអនុប្រធានគណៈកម្មាធិការប្រតិបត្តិ តាមសំណើរបស់ប្រធានគណបក្ស ។

គណៈកម្មាធិការនាយក អាចបង្កើតគណៈកម្មការនានាតាមការចាំបាច់ ។

**ប្រការ ២៧ ៖**

គណៈកម្មាធិការនាយក ត្រួតពិនិត្យការប្រតិបត្តិរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស និងអាចផ្ដួចផ្ដើមគំនិតឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍ដឹកនាំគណបក្សស្របតាមស្ថានការណ៍ និងកាលៈទេសៈជាក់ស្ដែងដើម្បីឲ្យគណបក្សមានការរីកចម្រើន ។

គណៈកម្មាធិការនាយកពិភាក្សា អនុម័តរាល់បទប្បញ្ញត្តិផ្សេងៗរបស់គណបក្ស តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ។

**ប្រការ ២៨ ៖**

គណៈកម្មាធិការនាយក ដឹកនាំដោយប្រធាន មួយរូប និងអនុប្រធាន យ៉ាងតិចមួយរូប ។

ប្រធានគណៈកម្មាធិការនាយក ជ្រើសតាំងដោយសមាជិកគណៈកម្មាធិការនាយក តាមរយៈការបោះឆ្នោតសម្ងាត់ដោយសម្លេងភាគច្រើន (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

បេក្ខជនប្រធានគណៈកម្មាធិការនាយក ជាសមាជិកគណៈកម្មាធិការនាយក ដែលមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

អនុប្រធានគណៈកម្មាធិការនាយក ត្រូវបានផ្តល់សេចក្តីទុកចិត្តដោយសម្លេងភាគច្រើន (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល តាមសំណើរបស់ប្រធានគណៈកម្មាធិការនាយក ។

**ប្រការ ២៩ ៖**

គណៈកម្មាធិការនាយក មានអាណត្តិ៥ឆ្នាំ ។ សមាជិកគណៈកម្មាធិការនាយកចាស់នឹងអស់សុពលភាពនៅពេលសមាជិកគណៈកម្មាធិការនាយកថ្មីចូលកាន់តំណែង ។

**ប្រការ ៣០ ៖**

គណៈកម្មាធិការនាយក ជួបប្រជុំគ្នាយ៉ាងតិច ៣ខែម្តង ។ ក្នុងករណីពិសេស ប្រធានគណបក្ស ឬប្រធានគណៈកម្មាធិការនាយក ឬសំណើ ១/៣ នៃសមាជិកគណៈកម្មាធិការនាយកមានសិទ្ធិកោះប្រជុំគណៈកម្មាធិការនាយក ។

នីតិវិធីនៃកិច្ចប្រជុំគណៈកម្មាធិការនាយក មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

## ផ្នែកទី ៤

## គណៈកម្មាធិការវិន័យ

**ប្រការ ៣១ ៖**

គណៈកម្មាធិការវិន័យ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការនាយក ។

គណៈកម្មាធិការវិន័យ មានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ទទួលពាក្យបណ្តឹងវិវាទរបស់សមាជិកគណបក្ស

- ទទួលពាក្យបណ្ដឹងស្ដីពីភាពមិនប្រក្រតីនៃចំណូល-ចំណាយរបស់គណបក្ស
- ទទួលបណ្ដឹងឧទ្ធរណ៍ករណីបញ្ចប់សមាជិកភាពដោយគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត
- ដាក់ពិន័យសមាជិកគណបក្សរូបណា ដែលរំលោភបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ១៨ នៃលក្ខន្តិកៈគណបក្ស ។

នីតិវិធីនៃការដោះស្រាយបណ្ដឹង ការដាក់ពិន័យ និងការបញ្ចប់សមាជិកភាព មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

**ប្រការ ៣២ ៖**

គណៈកម្មាធិការវិន័យ មានសមាសភាពដូចតទៅ ៖

- ប្រធាន និងអនុប្រធានមួយរូប ជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួនដោយសម្លេងគាំទ្រភាគច្រើនដាច់ខាត (៥0%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល
- សមាជិក ប្រាំរូបទៀត ជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាតិដោយសម្លេងគាំទ្រភាគច្រើនដាច់ខាត (៥0%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល

បេក្ខជនប្រធាន និងអនុប្រធាន ត្រូវមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

**ប្រការ ៣៣ ៖**

គណៈកម្មាធិការវិន័យ មានអាណត្តិ ៥ឆ្នាំ ។ គណៈកម្មាធិការវិន័យចាស់នឹងអស់សុពលភាពបន្ទាប់ពីគណៈកម្មាធិការវិន័យថ្មីចូលកាន់តំណែង ។

**ប្រការ ៣៤ ៖**

ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការវិន័យ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

# ផ្នែកទី ៥

# គណៈកម្មាធិការប្រតិបត្តិ

**ប្រការ ៣៥ ៖**

គណៈកម្មាធិការប្រតិបត្តិ ជាស្ថាប័ននីតិប្រតិបត្តិរបស់គណបក្ស ។ គណៈកម្មាធិការប្រតិបត្តិគ្រប់គ្រង និងជានាការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុ ព្រមទាំងរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ និងសាខាគណបក្សនៅក្រៅប្រទេស ។

គណៈកម្មាធិការប្រតិបត្តិ អនុវត្តការងារប្រចាំថ្ងៃតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្រោមការត្រួតពិនិត្យរបស់ប្រធាន និងអនុប្រធានគណបក្ស ។

**ប្រការ ៣៦ ៖**

គណៈកម្មាធិការប្រតិបត្តិ មានសមាសភាពជ្រើសចេញមកពីសមាជិកគណៈកម្មាធិការនាយក ៖

- ប្រធាន មួយរូប
- អនុប្រធាន យ៉ាងតិចមួយរូប
- អគ្គនាយក មួយរូប អមដោយអគ្គនាយករង មួយរូប នៃអគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គនាយក មួយរូប អមដោយអគ្គនាយករង មួយរូប នៃអគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ
- អគ្គនាយក មួយរូប អមដោយអគ្គនាយករង មួយរូប នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុ ។

អនុប្រធានគណៈកម្មាធិការប្រតិបត្តិ ទទួលការងារតាមការកំណត់របស់ប្រធានគណៈកម្មាធិការប្រតិបត្តិ ។

ប្រធាន និងអនុប្រធានគណៈកម្មាធិការប្រតិបត្តិ តែងតាំងដោយប្រធានគណបក្ស បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការនាយក ដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

**ប្រការ ៣៧ ៖**

គណៈកម្មាធិការប្រតិបត្តិ មានអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុ ជាសេនាធិការ ។

អគ្គនាយក និងអគ្គនាយករង នៃអគ្គនាយកដ្ឋានទាំងបី តែងតាំងដោយប្រធានគណបក្ស តាមសំណើរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការនាយកដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

**ប្រការ ៣៨ ៖**

អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុ មាននាយកដ្ឋានមួយចំនួនតាមតម្រូវការចាំបាច់ ។ នាយកដ្ឋាននីមួយៗ ដឹកនាំដោយ ប្រធានមួយរូប និងអនុប្រធានមួយរូប ដែលតែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិ តាមសំណើរបស់អគ្គនាយក ។

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុ កំណត់ដោយគណៈកម្មាធិការប្រតិបត្តិ ។

**ប្រការ ៣៩ ៖**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុ ទទួលបន្ទុកគ្រប់គ្រងថវិកា និងបញ្ជីសារពើភ័ណ្ឌទាំងអស់របស់គណបក្ស ។

**ប្រការ ៤០ ៖**

អគ្គនាយកហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីប្រាក់ចំណូល-ចំណាយរបស់គណបក្ស ជូនប្រធាន អនុប្រធានគណបក្ស ប្រធានគណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការនាយក ។

**ប្រការ ៤១ ៖**

ប្រធានគណៈកម្មាធិការប្រតិបត្តិ ឬអនុប្រធានដែលបានទទួលសិទ្ធិពីប្រធាន អាចកោះប្រជុំ និងដឹកនាំអង្គប្រជុំនៃគណៈកម្មាធិការប្រតិបត្តិដោយមិនគិតកូរ៉ុម ដើម្បីប្រតិបត្តិការងារប្រចាំថ្ងៃ ស្របតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ។

គណៈកម្មាធិការប្រតិបត្តិមានអាណត្តិ ៥ឆ្នាំ ។ គណៈកម្មាធិការប្រតិបត្តិចាស់នឹងអស់សុពលភាពបន្ទាប់ពីគណៈកម្មាធិការប្រតិបត្តិថ្មីចូលកាន់តំណែង ។

## ផ្នែកទី ៦
## គណៈកម្មាធិការអចិន្ត្រៃយ៍

**ប្រការ ៤២ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍ដឹកនាំ ចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្ស ។

គណៈកម្មាធិការអចិន្ត្រៃយ៍ មានសិទ្ធិសម្រេចលើគ្រប់បញ្ហា និងការងារចាំបាច់ រួមទាំងការបញ្ចប់សមាជិកភាពហើយ និងស្នើសុំឲ្យប្រធានគណបក្ស តែងតាំង ឬដកតួនាទី ឬព្យួរតំណែង មន្ត្រីគណបក្សគ្រប់លំដាប់ថ្នាក់ ។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ទទួលខុសត្រូវលើរាល់សេចក្តីសម្រេចទាំងនោះ នៅចំពោះមុខគណៈកម្មាធិការនាយក ។

**ប្រការ ៤៣ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស រៀបចំគម្រោងផែនការធំៗ ដាក់ជូនគណៈកម្មាធិការនាយកពិនិត្យ មុននឹងដាក់ជូនសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិ ពិភាក្សា និងអនុម័ត ។

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានចំនួនយ៉ាងច្រើន ២៩រូប ដែលមានសមាសភាពដូចតទៅ ៖

- ប្រធាន និងអនុប្រធានគណបក្ស
- ប្រធាន និងអនុប្រធានគណៈកម្មាធិការនាយក
- ប្រធាន និងអនុប្រធានគណៈកម្មាធិការវិន័យ
- ប្រធាន និងអនុប្រធានគណៈកម្មាធិការប្រតិបត្តិ
- អគ្គនាយករដ្ឋបាល និងអគ្គនាយករង
- អគ្គនាយកទំនាក់ទំនងសាធារណៈ និងអគ្គនាយករង
- អគ្គនាយកហិរញ្ញវត្ថុ និងអគ្គនាយករង
- និងសមាជិកមួយចំនួន ដែលជ្រើសរើសដោយគណៈកម្មាធិការនាយក ពីក្នុងចំណោមសមាជិករបស់ខ្លួន តាមសម្លេងភាគច្រើនដាច់ខាត (៥0%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

ប្រធាន និងអនុប្រធានគណបក្ស ជាប្រធាន និងអនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ។

កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ អាចប្រព្រឹត្តទៅបានតាមការសម្រេចរបស់ប្រធាន ឬតាមសំណើចំនួន ១/៣ នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយចាំបាច់ត្រូវមានកូរ៉ុម ២/៣ នៃសមាជិកទាំងមូល ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវមានសម្លេងគាំទ្រភាគច្រើនដាច់ខាត (៥0%+១) នៃសមាជិកទាំងមូល ។

**ប្រការ ៤៤ ៖**

ប្រធាន និងអនុប្រធានគណបក្ស ត្រូវបានជ្រើសតាំងដោយសមាជ តាមរយៈការអនុម័តបញ្ជីបេក្ខជនដោយសម្លេងភាគច្រើនដាច់ខាត (៥0%+១) នៃសមាជិកវត្តមានដែលមានសិទ្ធិសម្រេច សម្រាប់អាណត្តិ ៥ឆ្នាំ។

បញ្ជីបេក្ខជន គឺជាបញ្ជីរួមរបស់បេក្ខជនប្រធាន និងអនុប្រធានគណបក្ស ។ បញ្ជីនេះត្រូវមានការគាំទ្រពីសមាជិកគណៈកម្មាធិការនាយកចំនួនយ៉ាងតិច ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

ឥស្សរជននយោបាយក្នុងគណបក្សមួយរូប អាចធ្វើជាប្រធានគណបក្សត្រឹមពីរអាណត្តិ(១០ឆ្នាំ) ។

**ប្រការ ៤៥ ៖**

អនុប្រធានគណបក្ស ទទួលដឹកនាំការងារគណបក្សតាមការកំណត់របស់ប្រធានគណបក្ស ។

នៅពេលអវត្តមានប្រធាន អនុប្រធានត្រូវបានទទួលសិទ្ធិជាប្រធានគណបក្សស្តីទី ដែលមានបុព្វសិទ្ធិដូចប្រធានគណបក្ស ។

ក្នុងករណីអវត្តមានប្រធាន និងអនុប្រធាន អ្នកទទួលសិទ្ធិជាប្រធានគណបក្សស្តីទី ត្រូវជ្រើសតាមឋានានុក្រមដូចខាងក្រោម ៖

១- ប្រធានគណៈកម្មាធិការនាយក

២- ប្រធានគណៈកម្មាធិការវិន័យ

៣- ប្រធានគណៈកម្មាធិការប្រតិបត្តិ

៤- អនុប្រធានគណៈកម្មាធិការនាយក

៥- អនុប្រធានគណៈកម្មាធិការវិន័យ

៦- អនុប្រធានគណៈកម្មាធិការប្រតិបត្តិ

ការទទួលសិទ្ធិជាប្រធានគណបក្សស្តីទីនេះ ត្រូវធ្វើតាមរយៈលិខិតផ្ទេរសិទ្ធិពីប្រធានគណបក្ស ។

**ប្រការ ៤៦ ៖**

ប្រធានគណបក្ស មានខុទ្ទកាល័យមួយ ដើម្បីជួយដល់កិច្ចការផ្ទាល់របស់ខ្លួន ។ ខុទ្ទកាល័យប្រធានគណបក្សដឹកនាំដោយនាយខុទ្ទកាល័យមួយរូប អមដោយនាយរងខុទ្ទកាល័យមួយចំនួនដែលតែងតាំងដោយប្រធានគណបក្ស ។

ប្រធានគណបក្ស តែងតាំង ឬផ្លាស់ប្តូរបេក្ខជនតំណាងរាស្ត្រ បេក្ខជនសមាជិកព្រឹទ្ធសភា និងបេក្ខជនថ្នាក់ដឹកនាំដទៃទៀត តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

ប្រធានគណបក្ស មានសិទ្ធិតែងតាំង ឬដកតួនាទី បេសកជន និងទីប្រឹក្សាផ្ទាល់របស់ខ្លួន ។

**ប្រការ ៤៧ ៖**

ករណីប្រធានគណបក្សបាត់បង់សមត្ថភាពដឹកនាំគណបក្ស ដែលបញ្ជាក់ដោយគណៈកម្មាធិការនាយក បើ ៖

- អាណត្តិនៅតិចជាង១៨ខែ អនុប្រធានគណបក្ស ត្រូវទទួលនាទីជាប្រធានគណបក្សស្តីទី ហើយគណៈកម្មាធិការនាយកត្រូវជ្រើសរើសអនុប្រធានគណបក្សថ្មីមួយរូប ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរពីក្នុងចំណោមសមាជិករបស់ខ្លួន ដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ដើម្បីជួយការងារប្រធានគណបក្សស្តីទី រហូតដល់ចប់អាណត្តិ

- អាណត្តិនៅលើស១៨ខែ គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវកំណត់ពេលរៀបចំធ្វើសមាជវិសាមញ្ញ ដើម្បីជ្រើសរើសប្រធានគណបក្ស និងអនុប្រធានគណបក្សថ្មីក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ ដើម្បីដឹកនាំគណបក្សរហូតដល់ចប់អាណត្តិ ។

## ផ្នែកទី ៧
## រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ

**ប្រការ ៤៨ ៖**

រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ មាន ៖

- តំណាងគណបក្សភូមិ
- គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់
- គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ
- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត

នីតិវិធី នៃការរៀបចំរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ មានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

## ជំពូកទី ៦
## ធនធាន និងថវិការបស់គណបក្ស

**ប្រការ ៤៩ ៖**

ធនធាន និងថវិការបស់គណបក្សបានមកពី ៖

- ភាគទានរបស់សមាជិក
- អំណោយពីគ្រប់មជ្ឈដ្ឋានដែលស្របច្បាប់
- សកម្មភាពស្របច្បាប់ក្នុងគ្រប់វិស័យ ។

**ប្រការ ៥០ ៖**

ធនធាន និងថវិកាគណបក្សគ្រប់គ្រងដោយអគ្គនាយកដ្ឋានហិរញ្ញវត្ថុគណបក្ស ។

គណៈកម្មាធិការនាយក ជ្រើសរើសស្នងការគណនេយ្យតាមសំណើរបស់គណៈកម្មាធិការវិន័យ ដើម្បីត្រួតពិនិត្យភាពមិនប្រក្រតីលើបញ្ជីចំណូល-ចំណាយនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## ការកែប្រែលក្ខន្តិកៈ និងការរំលាយគណបក្ស

**ប្រការ ៥១ ៖**

សមាជគណបក្ស គឺជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចធ្វើការកែប្រែលក្ខន្តិកៈ ឬរំលាយគណបក្ស ។

ការកោះប្រជុំសមាជ ក្នុងគោលបំណងកែប្រែលក្ខន្តិកៈ ឬរំលាយគណបក្ស ត្រូវមានការយល់ព្រមដោយសម្លេងភាគច្រើន (២/៣) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ហើយត្រូវមានការយល់ព្រមពីប្រធានគណបក្ស និងប្រធានគណៈកម្មាធិការវិន័យ ។

**ប្រការ ៥២ ៖**

ករណីគណបក្សត្រូវរំលាយ ទ្រព្យសម្បត្តិទាំងអស់របស់គណបក្ស បន្ទាប់ពីមានការជម្រះបញ្ជីរួចរាល់ត្រូវប្រគល់ជូនអង្គការមនុស្សធម៌នានា ដែលកំណត់ដោយសមាជចុងក្រោយរបស់គណបក្ស ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**ប្រការ ៥៣ ៖**

អន្តរប្បញ្ញត្តិ គឺជាប្បញ្ញត្តិសម្រាប់អនុវត្តនៅក្នុងអន្តរកាល ។ អន្តរកាល គឺជាដំណាក់កាលនៃការគ្រប់គ្រង និងដឹកនាំសម្រាប់អាណត្តិទី១របស់គណបក្ស ។

**ប្រការ ៥៤ ៖**

សមាជលើកទី១របស់គណបក្សសង្គ្រោះជាតិ ៖

- ជ្រើសតាំងប្រធាន និងអនុប្រធានគណបក្សតាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសម្លេងភាគច្រើនដាច់ខាត (៥0%+១) នៃសមាជិកចូលរួម តាមសំណើរបស់គណៈកម្មាធិការបណ្តោះអាសន្នគណបក្ស ដែលមានភារកិច្ចរៀបចំសមាជលើកទី១របស់គណបក្ស
- ជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិ និងសមាជិកគណៈកម្មាធិការនាយក តាមរយៈការបោះឆ្នោតដោយសម្លេងភាគច្រើនដាច់ខាត (៥0%+១) នៃសមាជិកដែលមានសិទ្ធិសម្រេច ដោយអនុម័តលើបញ្ជីបេក្ខជនដែលស្នើដោយប្រធាន និងអនុប្រធានគណបក្ស ។

**ប្រការ ៥៥ ៖**

ក្នុងអន្តរកាលនេះ ៖

- រាល់សេចក្តីសម្រេចត្រូវមានសម្លេងឯកច្ឆ័ន្ទរបស់ប្រធាន និងអនុប្រធានគណបក្ស
- គណៈកម្មាធិការនាយកសម្រេចដោយសម្លេងភាគច្រើនដាច់ខាត (៥0%+១) ដកតួនាទី ឬជ្រើសតាំងបន្ថែមសមាជិកគណៈកម្មាធិការនាយកតាមសំណើរបស់ប្រធាន និងអនុប្រធានគណបក្ស

**ប្រការ ៥៦ ៖**

ក្នុងករណីប្រធាន និងអនុប្រធានគណបក្សពុំមានសម្លេងឯកច្ឆ័ន្ទ ៖

- រាល់សេចក្តីសម្រេចគ្រប់ស្ថាប័នរបស់គណបក្ស (សមាជ សន្និបាតក្រុមប្រឹក្សាជាតិ គណៈកម្មាធិការទាំងបី និងគណៈកម្មាធិការអេចិន្ត្រៃយ៍...)ត្រូវទុកជាមោឃៈ និងមិនអាចយកទៅប្តឹងផ្តល់បានឡើយ
- ការងារគណបក្សប្រចាំថ្ងៃ (ដូចជាធ្វើរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុប្រចាំឆ្នាំជូនស្ថាប័នរដ្ឋ) ត្រូវដឹកនាំដោយគណៈកម្មការចំពោះកិច្ចមួយរហូតដល់ចប់អាណត្តិ ។ គណៈកម្មការចំពោះកិច្ចមាន សមាសភាព ៖
    - ប្រធានគណៈកម្មាធិការទាំងបី
    - អគ្គនាយករដ្ឋបាល
    - អគ្គនាយកហិរញ្ញវត្ថុ

  ប្រធានគណបក្ស ឬអនុប្រធាន (ករណីប្រធានគណបក្សអវត្តមាន) ត្រូវមានកាតព្វកិច្ចចុះហត្ថលេខាលើរបាយការណ៍នានា ដែលរៀបចំដោយគណៈកម្មការចំពោះកិច្ចនេះ ។
- គណបក្សមិនអាចរំលាយមុនបញ្ចប់អាណត្តិប្រធាន និងអនុប្រធានគណបក្សបានឡើយ ។

# ជំពូកទី ១០

# អវសានប្បញ្ញត្តិ

**ប្រការ ៥៧ ៖**

បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានារបស់គណបក្សត្រូវស្របនឹងលក្ខន្តិកៈរបស់គណបក្សជាដាច់ខាត ។

**ប្រការ ៥៨ ៖**

លក្ខន្តិកៈនេះត្រូវបានអនុម័តដោយសមាជលើកទី១របស់គណបក្ស ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៣ ។

លក្ខន្តិកៈនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណបក្ស ។

ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៣

**ប្រធានគណបក្ស**

**សម រង្ស៊ី**

# ឧបសម្ព័ន្ធទី១

## អត្ថន័យនៃរូបសញ្ញា

គណបក្សសង្គ្រោះជាតិ មានសញ្ញាសម្គាល់ ៖

- ព្រះអាទិត្យរះ បីភាគបួន (៣/៤) បំភ្លឺពិភពលោក បំភ្លឺព្រះរាជាណាចក្រកម្ពុជា
- ព្រះអាទិត្យរះបញ្ចេញកាំរស្មី២៤ តំណាងឲ្យរាជធានី-ខេត្ត ទាំង២៤ របស់ព្រះរាជាណាចក្រកម្ពុជា
- ព្រះអាទិត្យរះ លើផ្ទៃបួនជ្រុងស្មើពណ៌ខៀវ ជាពណ៌តំណាងឲ្យក្ដីសង្ឃឹម ក្ដីសង្ឃឹមរបស់ប្រជាជាតិយើង
- ព្រះអាទិត្យរះ ពីខាងលើអក្សរ "គណបក្សសង្គ្រោះជាតិ" បញ្ជាក់ឈ្មោះគណបក្ស ។